

# PreK 4 ME ការផ្សារភ្ជាប់គ្រួសារ

## មេរៀនទី 6 ៖ របស់ដែលលូតលាស់

### ***ទិដ្ឋភាពទូទៅនៃមេរៀនទី 6 ៖ របស់ដែលលូតលាស់***

*រុក្ខជាតិបានលូតលាស់ក្នុងនិទាឃរដូវ ហើយគឺជាពេលដែលរីករាយបំផុតក្នុងថ្នាក់រៀនរបស់យើង! យើងកំពុងប្រើជំនាញផ្នែកវិទ្យាសាស្ត្ររបស់យើង ដើម្បីសិក្សាថាតើរុក្ខជាតិ និងសត្វលូតលាស់ដោយរបៀបណា ។ ពីគ្រាប់ទៅជារុក្ខជាតិ គឺយើងនឹងនាំគ្នាស្វែងយល់ពីសួនច្បារនៅជុំវិញពិភពលោក ។ ក្នុងពេលរៀនមេរៀននេះ យើងនឹងឆ្លុះបញ្ចាំងមើលអំពីការលូតលាស់របស់យើងក្នុងឆ្នាំនេះ —ពាក់ព័ន្ធនឹងជំនាញនិងគំនិតរបស់យើង ក្នុងឆ្នាំសិក្សានេះ ។ ក្នុងនេះផងដែរ យើងក៏នឹងនាំគ្នាបន្តរៀនច្រៀងតាមពាក្យ និងជំនាញរាប់ និងត្រៀមខ្លួនឲ្យបានរួចរាល់ ក្នុងការជួយសិស្សរបស់យើង ធ្វើអន្តរកម្មឆ្លងចូលទៅសិក្សានៅថ្នាក់មត្តេយ្យ !*

## <u>សៀវភៅសំខាន់នៃមេរៀនទី 6</u>




*<u>The Ugly Vegetables</u>*

ដោយ Grace Lin




<u>Community Soup</u>

ដោយ Alma Fullerton




*<u>Chickens Aren't the Only Ones</u>*

ដោយ Ruth Heller




*<u>Zinnia's Flower Garden</u>*

ដោយ ៖ Monica Welling-

រូបភាពដកស្រង់ពី Amazon.com

### សៀវភៅផ្សេងទៀតដែលត្រូវអាន ៖

<u>Make Way for Ducklings</u>

ដោយ Robert McCloskey

<u>Animals Born Alive and Well</u>

ដោយ Ruth Heller



រូបភាពដកស្រង់ពី Pixabay

### ចម្រៀង ការលេងពាក្យ និងអក្សរ

*អានកំណាព្យនេះជាមួយកូនអ្នក ។ ឲ្យកូនអ្នករកពាក្យជួនគ្នាក្នុងកំណាព្យនេះ!*

*<u>ផ្កាស្បៃរឿង និងផ្កាឈូករ័ត្ន</u>*

ផ្កាស្បៃរឿង និងផ្កាឈូករ័ត្ន
ឱ ផ្កាដ៏ស្អាតអើយ!
អ្នកកំពុងនាំគ្នាបង្អួតសម្រស់នានិទាឃរដូវ
លាយជាមួយភ្លៀងធ្លាក់តិចៗ ។
ត្រួយ និងស្លឹកចាប់ផ្តើមលូតលាស់
ដុះឡើងចេញទៅក្នុងលំហអាកាស ។
ផ្កាស្បៃរឿង និងផ្កាឈូករ័ត្ន
អ្នករីកលូតលាស់គ្រប់ទីកន្លែង!



រូបភាពដកស្រង់ពី Pixabay

សូមអានទំព័រម្ខាងទៀតអំពីសកម្មភាពនៅផ្ទះ

# ចូរបង្កើតការរៀនសូត្រនៅផ្ទះ ដោយប្រើសកម្មភាពបន្ថែមទាំងអស់នេះ!

## បទដ្ឋានរៀនគណិតវិទ្យា វិធីសាស្ត្រសិក្សា

**ដើររាប់របស់ជុំវិញផ្ទះ**

នេះជាសកម្មភាពដែលងាយ ហើយធ្វើឲ្យក្មេងរីករាយ ដែលមិនបាច់ត្រូវប្រើសម្ភារៈអ្វីឡើយ! ជ្រើសរើសរបស់ដែលនៅជុំវិញផ្ទះរបស់អ្នក (ទ្វារ បង្អួច កម្រាលព្រំ ។ល។) ហើយឲ្យកូនអ្នករាប់របស់ទាំងនោះ! អ្នកអាចពិភាក្សាដោយសួរកូនអ្នកថា តើរបស់ណាមានច្រើនជាង របស់ណាមានតិចជាង ។

## អក្សរសាស្ត្រ ការលូតលាស់រាងកាយ គណិតវិទ្យា

**ពេលខ្លះខ្ញុំតូច**

នេះជាកំណាព្យដែលយើងបានបង្រៀនក្នុងថ្នាក់រៀន ចំពោះមេរៀននេះ ៖

**ជូនកាលខ្ញុំតូច**

(ក្រាបចុះ ហើយបង្រួមខ្លួនអ្នកឲ្យតូច)

**ពេលខ្លះខ្ញុំខ្ពស់**

(ងើបឈរ ហើយសន្ធឹងដងខ្លួនឲ្យខ្ពស់)

**តូច** (ក្រាមចុះ)

**ខ្ពស់** (ងើបឈរ និងសន្ធឹងដងខ្លួន)

## បទដ្ឋានអក្សរសាស្ត្រ ភាសា អារម្មណ៍សង្គម និងវិធីសាស្ត្ររៀនសូត្រ

**ចាប់ផ្តើមជាមួយនឹងការប្រមាញ់**

សរសេរអក្សរ 5 តួ ដាក់លើក្រដាសមួយសន្លឹក ។ សួរកូនអ្នកថាតើស្គាល់សម្លេងតួអក្សរនេះដែរឬទេ ។ រួចហើយ ឲ្យកូនអ្នករកមើលរបស់ដែលឈ្មោះ របស់វាចាប់ផ្តើមដោយសម្លេងតួអក្សរទាំងនោះ ។ អ្នកត្រូវរំឭកគាត់អំពីសម្លេងតួអក្សរទាំងអស់នោះ!

រូបភាពដកស្រង់ពី Pixabay



**បណ្តាំចំពោះគ្រួសារ និងអ្នកមើលថែក្មេង ៖**

ដោយសារថាយើងទាំងអស់គ្នាជិតឆ្លងឆ្នាំចាស់ ឈានចូលឆ្នាំថ្មី គឺយើងចាប់ផ្តើមគិតអំពីសកម្មភាពក្នុងរដូវក្តៅ ក៏ដូចជាការធ្វើអន្តរកម្មរបស់កូនអ្នកទៅកាន់ថ្នាក់មត្តេយ្យ ។ នេះគឺជាគន្លឹះមួយចំនួនសម្រាប់ជួយកូនអ្នក (និងអ្នក!) ៖

- ទៅមើលសាលាមត្តេយ្យឲ្យបានឆាប់ នៅរដូវក្តៅនេះ ។ បើសាលាអ្នករៀបចំថ្ងៃសម្រាប់ចូលមើសាលា ត្រូវព្យាយាមយកកូនអ្នកចូលរួម ។ បើសាលាមត្តេយ្យរបស់កូនអ្នក មានផ្តល់កាលវិភាគសកម្មភាពប្រចាំថ្ងៃ មុនថ្ងៃចូលរៀន ត្រូវពិនិត្យមើលកាលវិភាគនេះជាមួយកូនអ្នក ។ ថតរូបសាលា បន្ទប់រៀន និងគ្រូថ្មីទុក បើអាច
- ប្រាប់ឲ្យកូនអ្នកបានដឹងពីអារម្មណ៍របស់អ្នក ពេលអ្នកបានទៅសាលាមត្តេយ្យ—និងអ្វីដែលបានជួយឲ្យអ្នកមានអារម្មណ៍ធូរស្រាល និងអ្វីដែលធ្វើឲ្យស្ថានភាពល្អប្រសើរ (ទៅតាមអ្វីដែលអ្នកអាចនៅចាំបាន!)
- អានឲ្យកូនអ្នកស្តាប់ អំពីការចាប់ផ្តើមរៀននៅថ្នាក់មត្តេយ្យ ។